ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ២៦៩ សកបយ.

ភ្នំពេញ. ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## ការបង្កើតសៀវភៅបើកប្រាក់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សម្រេច

**ប្រការ១.**- នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវកាន់ដោយទៀងទាត់ជាដរាប នូវសៀវភៅបើកប្រាក់មួយដូចគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.**- សៀវភៅបើកប្រាក់នេះនឹងទុកជាត្រឹមត្រូវបាន លុះត្រាមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេបគ្រប់ទំព័រដោយអធិការការងារ។

និយោជក នៃសហគ្រាស គ្រឹះស្ថានណាចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីគំរូដូចមានចែង

ក្នុងប្រការ១ ខាងលើ ប៉ុន្តែមានចុះពតិមាន និងបែបបទត្រួតពិនិត្យដូចគ្នានោះ ត្រូវធ្វើពាក្យសុំទៅនាយកដ្ឋានអធិការកិច្ចការងារ ( ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ ) និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុងបាន ( ចំពោះសហគ្រាស គ្រឹះស្ថាននៅខេត្ត- ក្រុងផ្សេងទៀត ) ។

ប្រការ៣.- សៀវភៅបើកប្រាក់នេះត្រូវទុកនៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ ។ កាលណាប្រើសៀវភៅនេះគ្រប់ទំព័រហើយ និយោជកត្រូវមានកាតព្វកិច្ចរក្សាទុកអោយគង់វង់ក្នុងរយៈពេល ៣ឆ្នាំ ។

អធិការការងារ ឬអភិបាលការងារអាចទាររកសៀវភៅនេះ នៅគ្រប់ពេលវេលា ។

ប្រការ៤.- អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៥.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ៩៣ សកអ. ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងរាជការ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ
នៃប្រកាសលេខ........
ចុះថ្ងៃទី.......ខែ..........ឆ្នាំ

# សៀវភៅបើកប្រាក់
# LE LIVRE DE PAYE

**គ្រឹះស្ថាន**.....................
ETABLISSEMENT

**ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច**..........................
BRANCHE D'ACTIVITE ECONOMIQUE

**អាសយដ្ឋាន**..............................
ADDRESSE

( ទំហំ ២៥ ស.ម គុណ ៣៥ ស.ម )

# សៀវភៅបើកប្រាក់

# LE LIVRE DE PAYE

គ្រឹះស្ថាន ____________________

ETABLISSEMENT ____________________

ផ្នែកសកម្មភាពសេដ្ឋកិច្ច ____________________

BRANCHE D'ACTIVITE ECONOMIQUE ____________________

អាសយដ្ឋាន ____________________

ADRESSE ____________________

ប្រចាំខែ....................

| លរ<br>No | នាមត្រកូលនិងនាមខ្លួន នៃកម្មករ និយោជិត<br>Nom et prénom du salarié | សញ្ជាតិ<br>Natio-nalité | មុខងារកាន់កាប់ ក្នុងសហគ្រាស<br>Fonction occupée dans l'entreprise | ស្ថានភាពគ្រួសារ<br>Situation de famille<br>ប្រពន្ធ<br>Fem-me | <br><br>កូន<br>En-fant | ប្រាក់ថ្ងៃ ឬ ប្រាក់ខែ<br>Salaire journalier ou mensuel | វិភាគទាន គ្រួសារ<br>Alloca-tions famili-ales | ប្រាក់ម៉ោងធ្វើ ការបន្ថែម<br>Indemnité pour heures supplé-mentaires | ប្រាក់ជូនការ ឱ្យដំណឹងមុន ឬប្រាក់ខូចខាត ការឈប់<br>Preavis ou delai congé | ប្រាក់ឈប់ សំរាក ប្រចាំឆ្នាំ<br>Congé annuel payé | ប្រាក់រង្វាន់ ផ្សេងៗ<br>Autres Indem-nité ou primes |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

......ឆ្នាំ............ខែ　　　　　　　　　　　　　　　　ទំព័រ......................

| ចំនួនទឹកប្រាក់ទាំងអស់ដែលត្រូវបើក<br>Total des sommes à payer | ប្រាក់កាត់ទុក Retenues | | | | | ចំនួនប្រាក់ដែលកាត់ទាំងអស់<br>Total des retenues | ចំនួនប្រាក់ដែលត្រូវបើក<br>Montant net à payer | ហត្ថលេខា<br>Emargement | សេចក្ដីផ្សេងៗ<br>Observations |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនប្រាក់ខ្ចី<br>Montant des avances accordées | កាត់ប្រាក់ខ្ចី<br>Déduction des avances | ប្រាក់បន្ថយថ្ងៃឈប់<br>Déduction des journées de congé | ពន្ធ និងវិភាគទាន<br>Taxe et contribution | | | | | |
| | | | | សន្តិសុខសង្គម<br>Sécurité sociale | ពន្ធលើប្រាក់បៀវត្ស<br>ITS | | | | |
| 13(7+8+9+10+11+12) | 14 | 15 | 16 | 17 | 18 | 19(15+16+17+18) | 20(13-19) | 21 | 22 |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |